# សុន្ទរកថារបស់លោកអ៊ីអ៊ីស៊ឹកា តូម៉ុហ៊ីរ៉ូ
# លេខាទីពីរ ស្ថានទូតជប៉ុន
# ថ្លែងក្នុងពិធីសម្ពោធប្រព័ន្ធលូរំដោះទឹកតាមបណ្ដោយផ្លូវជាតិលេខ៥ក្នុងខេត្តបាត់ដំបង
# ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៤

**សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ!**

**សូមគោរព ឯកឧត្តម ចាន់ សុផល អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង!**

**សូមគោរព លោក ខាន់ ម៉ាណោរ ប្រធានមន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តបាត់ដំបង!**

**សូមគោរព ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់!**

ថ្ងៃនេះខ្ញុំមានសេចក្ដីសោមនស្សរីករាយខ្លាំងណាស់ដោយបានចូលរួមក្នុងពិធីសម្ពោធប្រព័ន្ធលូរំដោះទឹកតាមបណ្ដោយផ្លូវជាតិលេខ៥ក្នុងខេត្តបាត់ដំបងជាមួយវត្តមានដ៏ខ្ពង់ខ្ពស់របស់**ឯកឧត្តម ចាន់ សុផល**អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង។ ជាបឋម ខ្ញុំសូមសំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តបាត់ដំបង និងប្រជាជនក្នុងតំបន់ដែលបានរៀបចំឲ្យមានកម្មវិធីនេះឡើង។

ការការពារទឹកជំនន់គឺជាវិស័យអាទិភាពមួយនៃកិច្ចសហប្រតិបត្តិការរបស់ជប៉ុនសម្រាប់កម្ពុជា ហើយជាក់ស្ដែងគម្រោងកែលម្អប្រព័ន្ធលូរំដោះទឹកជាច្រើនត្រូវបានអនុវត្តទាំងនៅទីក្រុង និងតំបន់ជនបទ។ តួយ៉ាងនៅក្នុងខេត្តបាត់ដំបង គម្រោងសាងសង់លូរំដោះទឹកប្រវែង១,០៧០ម៉ែត្រ តាមបណ្ដោយផ្លូវជាតិលេខ៥ចំណុចរង្វង់មូលព្រះនារាយណ៍ក្នុងក្រុងបាត់ដំបងទើបត្រូវបានអនុវត្តថ្មីៗនេះ។

ខ្ញុំបានទទួលដំណឹងថា គម្រោងសាងសង់ប្រព័ន្ធលូរំដោះទឹកក្នុងក្រុងបាត់ដំបងនេះបានផ្ដល់អត្ថប្រយោជន៍ដល់ប្រជាជន ជាង ១៨,០០០នាក់ ដែលរស់នៅក្នុងសង្កាត់ចំការសំរោង ក្នុងការធ្វើដំណើរទៅកាន់ផ្សារបឹងឈូក បេនឡាន និងសាលារៀនផងដែរ។ ដូចដែលយើងទាំងអស់គ្នាបានដឹងហើយថា ផ្លូវជាតិលេខ៥គឺជាសរសៃឈាមដ៏សំខាន់មួយនៃសេដ្ឋកិច្ចកម្ពុជា ដូច្នេះយើងសង្ឃឹមថាគម្រោងនេះមិនត្រឹមតែជួយកែលម្អការគ្រប់គ្រងទឹកជំនន់ និងការថែរក្សាបរិស្ថានអនាម័យ និងសុវត្ថិភាពក្នុងតំបន់តែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយសម្រួលដល់ការដឹកទំនិញ និងការធ្វើដំណើរឆ្លងកាត់របស់ប្រជាជននៅតំបន់ផ្សេងៗទៀតនៅក្នុងប្រទេស ជាពិសេសក្រុមហ៊ុនជប៉ុនជាច្រើនដែលមានចំណាប់អារម្មណ៍ក្នុងការវិនិយោគក្នុងប្រទេសកម្ពុជា។

ខ្ញុំសង្ឃឹមថា មន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តបាត់ដំបង នឹងថែទាំប្រព័ន្ធលូរំដោះទឹកនេះឲ្យបានល្អដើម្បីអ្នកទទួលផលអាចប្រើប្រាស់សមិទ្ធិផលទាំងនេះបានយ៉ាងមានប្រសិទ្ធភាព។

ជាចុងក្រោយនេះ ខ្ញុំសូមសំដែងនូវការកោតសរសើរចំពោះលោក-អ្នកទាំងអស់ដែលបានរួមចំណែកធ្វើឲ្យការអនុវត្តគម្រោងនេះប្រព្រឹត្តទៅបានយ៉ាងរលូន។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាប្រព័ន្ធលូរំដោះទឹកនេះនឹងក្លាយជានិមិត្តរូបនៃមិត្តភាពរវាងប្រទេសយើងទាំងពីរ ព្រមទាំងជួយពង្រឹងជាបន្តនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្ដាប់!